


# ការពិនិត្យមើលផ្ទៀងផ្ទាត់តាមអេឡិចត្រូនិច (EVV)

## ប្រព័ន្ធទូរស័ព្ទទំព័រកត់ត្រាពេលម៉ោងធ្វើការនៃកម្មវិធី IHSS

## ការចុះឈ្មោះអ្នកផ្ដល់សេវា

សម្រាប់ជំនួយបន្ថែម សូមទាក់ទងទៅការិយាល័យសេវាកម្មផ្នែកកម្មវិធី IHSS តាមលេខទូរស័ព្ទ (866) 376-7066 នៅពេលម៉ោងធ្វើការ ចាប់ពីថ្ងៃច័ន្ទ រហូតដល់ថ្ងៃសុក្រ ពីម៉ោង 8am ទៅម៉ោង 5pm ។



ដើម្បីចុះឈ្មោះសំរាប់ប្រព័ន្ធទូរស័ព្ទទំព័រកត់ត្រាពេលម៉ោងធ្វើការ (TTS) នៃកម្មវិធី IHSS សូមចុច (833) DIAL-EVV ឬ (833) 342-5388 ហើយ អ្នកនឹងឮសារសម្លេងដូចតទៅនេះ:

**"សូមថ្លែងអំណរគុណចំពោះអ្នកក្នុងការទូរស័ព្ទមកប្រព័ន្ធទូរស័ព្ទទំព័រកត់ត្រាពេលម៉ោងធ្វើការនៃកម្មវិធី IHSS ។ សូមជ្រើសរើសយកភាសាដែលអ្នកចូលចិត្តពីជម្រើសដូចតទៅនេះ អ្នកអាចធ្វើការជ្រើសរើសរបស់អ្នក នៅពេលណាក៏បាន" ។**

មួយតំណាក់ៗជាបន្តបន្ទាប់ សូមប្រើបន្ទះវាយលេខរបស់អ្នក ដើម្បីបញ្ចូលព័ត៌មានដែលបានស្នើសុំ ។

**សំរាប់ភាសាអង់គ្លេស សូមចុចលេខ 1 ។**

**សំរាប់ភាសាអេស្ប៉ាញ សូមចុចលេខ 2 ។**

**សំរាប់ភាសាអាមីនៀន សូមចុចលេខ 3 ។**

**សំរាប់ភាសាចិន សូមចុចលេខ 4 ។**

បន្ទាប់មក TTS នឹងសួរអ្នកដើម្បីបញ្ជាក់ថាតើ អ្នកគឺជាអ្នកផ្តល់សេវា ឬជាអ្នកទទួលជំនួយ។

TTS នឹងនិយាយថា "**បើអ្នកគឺជាអ្នកទទួលជំនួយ សូមចុចលេខ '1', បើអ្នកគឺជាអ្នកផ្តល់សេវា សូមចុចលេខ '2'"** ។

ដោយហេតុថា អ្នកគឺជាអ្នកផ្តល់សេវា អ្នកនឹងត្រូវចុចលេខ '2'



អ្នកនឹងត្រូវបាននាំយកទៅកាន់ម៉ឺនុយដើមដំបូង ។

បន្ទាប់មក TTS នឹងនិយាយថា "នេះគឺជាម៉ឺនុយដើមដំបូង ។ សូមជ្រើសរើសយកពីជម្រើសដូចតទៅនេះ ។ អ្នកអាចធ្វើការជ្រើសរើសរបស់អ្នក នៅពេលណាក៏បាន:

**សូមចុចលេខ 1 ដើម្បីចូលបណ្ដាញ**

**សូមចុចលេខ 2 ដើម្បីកំណត់ឡើងវិញនូវលេខកូដសម្ងាត់របស់អ្នក**

**សូមចុចលេខ 3 សំរាប់ការចុះឈ្មោះ"**

ដោយហេតុថា អ្នកចង់ចុះឈ្មោះសំរាប់ TTS, សូមចុចលេខ 3




សំរាប់ផ្នែកបន្ទាប់ អ្នកនឹងត្រូវការមានព័ត៌មានដូចតទៅនេះ ដែលត្រូវរៀបចំជាស្រេច ហើយអាចប្រើប្រាស់បាន ។

- លេខកូដចុះឈ្មោះ 6 ខ្ទង់ របស់អ្នក ។
  - លេខកូដចុះឈ្មោះរបស់អ្នកគឺត្រូវបានផ្ញើទៅជូនអ្នកពីពេលមុន ។ បើសិនជាអ្នកមិនអាចរកវាឃើញនោះទេ សូមទំនាក់ទំនងទៅការិយាល័យខោនធីក្នុងតំបន់របស់អ្នក ។
- លេខអ្នកផ្ដល់សេវារបស់អ្នក ។
  - លេខអ្នកផ្ដល់សេវារបស់អ្នកគួរតែជាតួលេខ 9 ខ្ទង់ ហើយដែលអាចរកឃើញនៅលើកន្ទុយសែកប្រាក់ខែរបស់អ្នក ។
- កាលបរិច្ឆេទកំណើត ។

បន្ទាប់មក TTS នឹងរំលឹកប្រាប់អ្នកថា:

**ដើម្បីបន្ត សូមចុចលេខ 1" ។**

**ដើម្បីត្រឡប់ទៅម៉ឺនុយដើមដំបូង សូមចុចលេខ 9 ។**

**បើសិនជាអ្នកមិនមានលេខកូដចុះឈ្មោះទេ សូមចុចលេខ 0 សំរាប់ជំនួយ ។**

បើសិនជាអ្នកចុចលេខ 0 អ្នកនឹងត្រូវបញ្ជូនទៅកាន់ការិយាល័យសេវាកម្មផ្នែកកម្មវិធី IHSS ។

TTS នឹងនិយាយថា "**ដោយប្រើបន្ទះលេខទូរស័ព្ទរបស់អ្នក សូមបញ្ចូលលេខកូដចុះឈ្មោះ 6 ខ្ទង់របស់អ្នក អមដោយគ្រាប់ចុចសញ្ញាទ្រុងជ្រូក (#) ។ លេខកូដចុះឈ្មោះរបស់អ្នក ត្រូវបានផ្ញើជូនទៅអ្នក កាលពីកាលបរិច្ឆេទមុន**" ។

បន្ទាប់មក TTS នឹងនិយាយថា "**សូមបញ្ចូលលេខអ្នកផ្តល់សេវា 9 ខ្ទង់របស់អ្នក អមដោយគ្រាប់ចុចសញ្ញាទ្រុងជ្រូក (#)**" ។

លេខអ្នកផ្តល់សេវារបស់អ្នក អាចត្រូវបានរកឃើញនៅលើ កន្ទុយសែកប្រាក់ខែរបស់អ្នក ឬក្រដាសស្នាមដែលមានព័ត៌មានជាក់លាក់របស់ អ្នកផ្តល់សេវារបស់អ្នក ដែលបានផ្ញើទៅជូនអ្នកពីការិយាល័យ IHSS ។

TTS នឹងនិយាយថា "**សូមបញ្ចូលកាលបរិច្ឆេទកំណើតរបស់អ្នក អមដោយគ្រាប់ចុចសញ្ញាទ្រុងជ្រូក (#)**" ។ **កាលបរិច្ឆេទកំណើតរបស់អ្នកគួរតែបញ្ចូលជា លេខ 2 ខ្ទង់សំរាប់ខែ លេខ 2 ខ្ទង់សំរាប់ថ្ងៃ និង លេខ 4 ខ្ទង់សំរាប់ឆ្នាំ ។ ឧទាហរណ៍ បើកាលបរិច្ឆេទកំណើតរបស់អ្នកគឺជាថ្ងៃទី 12 ខែឧសភា ឆ្នាំ 1976, ដូច្នេះ អ្នកនឹងត្រូវបញ្ចូលលេខ 0 5 1 2 1 9 7 6 ។ សូមបញ្ចូលកាលបរិច្ឆេទកំណើតរបស់អ្នក អមដោយគ្រាប់ចុចសញ្ញាទ្រុងជ្រូក (#) ។**

ឧទាហរណ៍: ថ្ងៃទី 01 ខែឧសភា ឆ្នាំ 2019

**ខែ: ឧសភា ថ្ងៃ: 01 ឆ្នាំ: 2019#**




បើសិនជាអ្នកបញ្ចូលលេខមិនត្រឹមត្រូវណាមួយ, TTS នឹងប្រាប់ឱ្យអ្នកដឹងថាព័ត៌មាននេះគឺមិនត្រឹមត្រូវ ហើយនឹងប្រាប់ឱ្យអ្នកវាយបញ្ចូលលេខទាំងនោះម្តងទៀត ។

បើសិនជាអ្នកបញ្ចូលលេខទាំងនោះ មិនត្រឹមត្រូវម្តងទៀតនោះ, TTS នឹងប្រាប់ឱ្យអ្នកចុចលេខ 0 សំរាប់ជំនួយ ។ អ្នកនឹងត្រូវបានបញ្ជូនទៅការិយាល័យសេវាកម្មផ្នែកកម្មវិធី IHSS ។

នៅពេលដែលអ្នកបញ្ចូលលេខទាំងនោះបានត្រឹមត្រូវរួចហើយ អ្នកនឹងឮសារសម្លេងដូចតទៅនេះ:

**"ព័ត៌មានរបស់អ្នកត្រូវបានបញ្ជាក់បន្ថែមហើយ ។ ឥឡូវនេះ អ្នកនឹងត្រូវបង្កើតលេខកូដសម្ងាត់របស់អ្នក ។ លេខកូដសម្ងាត់របស់អ្នកនឹងត្រូវជាលេខ 4 ខ្ទង់ ដែលអ្នកនឹងប្រើរៀងរាល់ពេលដែលអ្នកចូលទៅក្នុងប្រព័ន្ធទូរស័ព្ទទំព័រកត់ត្រាពេលម៉ោងធ្វើការនៃកម្មវិធី IHSS ។ ដោយប្រើបន្ទះលេខទូរស័ព្ទរបស់អ្នក សូមបញ្ចូលលេខ 4 ខ្ទង់ ដែលអ្នកចង់ប្រើធ្វើជាលេខកូដសម្ងាត់ អមដោយគ្រាប់ចុចសញ្ញាទ្រុងជ្រូក (#)" ។**

សូមចងចាំក្នុងការរក្សាទុកលេខកូដសម្ងាត់របស់អ្នក ឱ្យមានសុវត្ថិភាព និង មិនត្រូវចែករំលែកអក្សរសម្ងាត់របស់អ្នកជាមួយនរណាម្នាក់ឡើយ ។

នៅពេលដែលអ្នកបំពេញផ្នែកលេខកូដសម្ងាត់រួចហើយ អ្នកនឹងឮ:

**"សូមអបអរសាទរ! ការចុះឈ្មោះរបស់អ្នកត្រូវបានបំពេញរួចហើយ និងក្នុងពេលឥឡូវនេះ អ្នកត្រូវបានចុះឈ្មោះដើម្បីប្រើប្រព័ន្ធទូរស័ព្ទទំព័រកត់ត្រាពេលម៉ោងធ្វើការនៃកម្មវិធី IHSS ហើយ ។ ឥឡូវនេះ អ្នកនឹងត្រូវបាននាំយកទៅកាន់ម៉ឺនុយដើមដំបូង ដើម្បីចូលទៅបណ្តាញ ឬ អ្នកអាចទម្លាក់ចុះនូវការហៅទូរស័ព្ទនេះ" ។**

ឥឡូវនេះ អ្នកអាចប្រើលេខកូដសម្ងាត់របស់អ្នក និង ស្វែងរុករកតាមរយៈ TTS ដើម្បីបញ្ចូលពេលម៉ោងដែលបានធ្វើការរបស់អ្នក ហើយនិង ដាក់ស្នើទំព័រកត់ត្រាពេលម៉ោងធ្វើការរបស់អ្នក ទៅឱ្យអ្នកទទួលជំនួយពិនិត្យឡើងវិញ យល់ព្រម ឬ បដិសេធ ។

សូមចងចាំថា ក្នុងនាមជាអ្នកផ្តល់សេវា អ្នកក៏អាចធ្វើកិច្ចការដូចតទៅនេះ នៅក្នុង TTS បានផងដែរ:

- បញ្ចូលម៉ោងដែលអ្នកបានធ្វើការ នៅលើទំព័រកត់ត្រាពេលម៉ោងធ្វើការរបស់អ្នកតាមទូរស័ព្ទ
- ពិនិត្យឡើងវិញនូវទំព័រកត់ត្រាពេលម៉ោងធ្វើការរបស់អ្នកតាមទូរស័ព្ទ
- ដាក់ស្នើទំព័រកត់ត្រាពេលម៉ោងធ្វើការរបស់អ្នក សំរាប់ឱ្យអ្នកទទួលជំនួយពិនិត្យឡើងវិញ និង ទទួលការយល់ព្រម ឬ ការបដិសេធពីអ្នកទទួលជំនួយ